**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Nov-2011, 13:18
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ:/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការជូនដំណឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ទាក់ទងនឹងសេចក្តីសន្និដ្ឋានបើក និង ការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់របស់ជនជាប់ចោទនៅសវនាការ

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់ អៀង ធីរិទ្ធ** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក ផាត់ ពៅស៊ាង | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| កញ្ញា Diana ELLI, QC | ចៅក្រម Silvia CARTWRIGHT | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** |
| | ចៅក្រម Jean-Marc LAVERGNE | PICH Ang |
| | ចៅក្រម យូ ឧត្តរា | Elisabeth SIMONNEAU FORT |

១. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងជូនដំណឹងដល់ភាគីតាមរយៈសារអេឡិចត្រូនិកថា សេចក្ដីសន្និដ្ឋានបើកនៅក្នុងករណី ០០២ នឹងចាប់ផ្ដើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលត្រូវបានបញ្ជាក់នៅពេលក្រោយនៅក្នុងអនុស្សរណៈមួយ[1] ។ អនុលោមតាមវិធាន ៨៩ស្ទួន ក្រុមមេធាវីការពារក្ដីនីមួយៗមានរយៈពេលកន្លះថ្ងៃដើម្បីធ្វើសេចក្ដីសន្និដ្ឋានបើករបស់ខ្លួន ដោយរួមទាំងការថ្លែងណាមួយពីជនជាប់ចោទ ។

២. ក្រុមមេធាវីការពារក្ដីកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នៅក្នុងអនុស្សរណៈរបស់ពួកគេចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ ថា[2] សហព្រះរាជអាជ្ញាបានកត់សម្គាល់ថាជនជាប់ចោទអាចធ្វើការឆ្លើយតបទៅនឹងសំណួរណាមួយបន្ទាប់ពីការបើកសវនាការលើអង្គសេចក្ដីនៅថ្ងៃទី២៨ ខែវិច្ឆិការ ឆ្នាំ២០១១ ។

៣. ដូចដែលបានចង្អុលបង្ហាញកាលពីលើកមុន និងមានចែងនៅក្នុងសំណើដែលដាក់នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១[3] មេធាវីការពារក្ដីមិនអាចទទួលបាននូវការណែនាំពីជនជាប់ចោទបានឡើយ ដោយសារស្ថានភាពស្មារតីរបស់គាត់ និងជាពិសេសការចុះអន់ថយនៃការចងចាំរបស់គាត់ ។ ដោយសារតែការអសមត្ថភាពបែបនេះ ទើបជនជាប់ចោទមិនអាចចូលរួមប្រកបដោយអត្ថន័យនៅក្នុងការរៀបចំរៀបចំការពារខ្លួនសម្រាប់ការជំនុំជម្រះក្ដីបានឡើយ ហើយគាត់ក៏មិនអាចបង្ហាញករណីរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាបានដែរ ។ គាត់មិនអាចយល់ពីសំណួរទាំងឡាយដែលចោទសួរមកលើរូបគាត់បានឡើយ ហើយក៏មិនអាចឆ្លើយតបទៅនឹងសំណួរទាំងនោះដោយសមហេតុផល

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង កាលបរិច្ឆេទសម្រាប់ដាក់តវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងការឆ្លើយតបទៅនឹងសំណើ E109/5 ចុះថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០១១ ឯកសារលេខ E131/1 ។

[2] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការឆ្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការផ្ដល់សក្ខីកម្មរបស់ជនជាប់ចោទ (E101/1) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១, ឯកសារ E101/5 ។

[3] ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ "បញ្ជីឯកសារដែលត្រូវដាក់នៅចំពោះអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវកោះហៅឲ្យចូលខ្លួនក្នុងអំឡុងពេលបីសប្ដាហ៍ដំបូងនៃការជំនុំជម្រះសេចក្ដី ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១ (បច្ចុប្បន្ននេះពុំមានលេខឯកសារទេ) ។

និងស៊ីចង្វាក់គ្នាបានដែរ។ ដោយសារតែការបាត់បង់នូវការចង់ចាំក្នុងរយៈពេលវែង និងរយៈពេលខ្លី ទើបជនជាប់ចោទមិនអាចផ្តល់ព័ត៌មានទាក់ទងនឹងសកម្មភាព និងតួនាទីរបស់គាត់ក្នុងអំឡុងពេលដែលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាពិសេសនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ហើយក៏មិនអាចរំលឹកឡើងវិញនូវព្រឹត្តិការណ៍ ដែលមានលក្ខណៈទូទៅនៅដំណាក់ដំបូងនៃជីវិតរបស់គាត់ និងព្រឹត្តិការណ៍នានាដែលកើតឡើងក្នុងអំឡុងពេលប៉ុន្មានឆ្នាំបន្ទាប់ពីការដួលរំលំនៃរបបកម្ពុជាប្រជាធិបតេយ្យបានដែរ ។ អាស្រ័យហេតុដូច្នេះ គាត់នឹងមិនអាចធ្វើសេចក្តីថ្លែងណាមួយក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបើកបានឡើយ ហើយគាត់ក៏មិនអាចផ្តល់សក្ខីកម្មនៅពេលសវនាការបានដែរ នៅក្នុងការអនុវត្តសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះ ។ នៅក្នុងកាលៈទេសៈបែបនេះ មេធាវីការពារក្តីចាំបាច់ផ្តត្រូវផ្តល់ការចង្អុលបង្ហាញនេះដល់អង្គជំនុំជម្រះសាលាដំបូងដោយមិនមានលទ្ធភាពធ្វើការពិភាក្សាប្រកបដោយអត្ថន័យស្តីអំពីបញ្ហានេះជាមួយអ្នកស្រី អៀង ធីរិទ្ធ ឡើយ ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | ATTORNEY AT LAW<br>KINGDOM OF CAMBODIA |